# ចម្លាក់គូឌុក្នុងសិល្បៈខ្មែរ

គូឌុ ជាចម្លាក់ដែលមានរាងដូចក្រចកដែលលេចឡើងដំបូងនៅក្នុងសិល្បៈឥណ្ឌា។ ចម្លាក់នេះគេលម្អនៅលើផ្ទឹមក្បាលជញ្ជាំង ឬតាមថ្នាក់ដំបូលនៃប្រាសាទ ហើយបើនៅឥណ្ឌាគេច្រើនដាក់នៅតាមច្រកទ្វារចូលទីសក្ការក្នុងរូងភ្នំ។ ពាក្យ "គូឌុ" គឺជាពាក្យក្លាយមកពាក្យ "តមុល" ដែលមានន័យថា "សំបុក" ហើយតំណាងឱ្យភាពខ្ពង់ខ្ពស់ ដ្បិត "សំបុក" តែងតែស្ថិតនៅលើទីខ្ពស់។[១] អ្នកស្រាវជ្រាវប្រវត្តិសិល្បៈ និងបុរាណវិទ្យា តែងតែហៅឈ្មោះចម្លាក់គូឌុនេះផ្សេងៗគ្នា ដូចជា ចៃត្យ (Caitya-Window) គូឌុ (Kūdu) គវាក្ស (gavākṣa) ប៉ុន្តែលោក G. Jouveau-Ouveau-Dybreull បញ្ជាក់ថាឈ្មោះ "គូឌុ" គឺជាឈ្មោះដែលគេនិយមហៅជាងគេនៅក្នុងសិល្បៈឥណ្ឌា។[២]

ជាទូទៅ រូបរាងរបស់ចម្លាក់គូឌុមានជាតុផ្សំសំខាន់ៗដូចជា មានក្បាលសសរ (ខ្វះក៏មិនមាន) មានស្លាបឬត្រចៀកនៅសងខាង មានរាងដូចក្រចកនៅលើក្បាលសសរ (ឥណ្ឌាហៅថា "Mukhapaṭṭi") មានឬគ្មានក្បាច់កំពោយនៅខាងលើ (ឥណ្ឌាហៅថា "Śikhā") មានឬគ្មានចម្លាក់រូបក្បាលមនុស្សឬទេពឬក្បាច់រុក្ខជាតិនៅខាងក្នុង (ឥណ្ឌាហៅថា "Gāḍha")។[៣]

នៅក្នុងសិល្បៈខ្មែរ ចម្លាក់គូឌុគេនិយមប្រើប្រាស់នៅសម័យមុនអង្គរ រវាងស.វ.ទី៦ ដល់ចុងស.វ.ទី៨[៤] ហើយគេអាចចែកចេញជា ៣ ប្រភេទធំៗ គឺ៖

ប្រភេទទី១៖ ចម្លាក់គូឌុធម្មតា មិនមានក្បាច់ចម្លាក់លម្អ ដែលយើងឃើញមាននៅក្នុងរចនាបថភ្នំដា ឧទាហរណ៍ ចម្លាក់គូឌុនៅលើក្បាលជញ្ជាំងច្រកចូលរូងភ្នំដា (រូបលេខ១) និងថ្នាក់ៗកំពូលប្រាសាទអាស្រមមហាឥសី (ភ្នំដា) (រូបលេខ២)។

ប្រភេទទី២៖ ចម្លាក់គូឌុ មានលម្អក្បាច់រុក្ខជាតិនៅខាងក្នុង ដែលយើងឃើញមានច្រើននៅលើសំណង់ប្រាសាទឥដ្ឋក្នុងរចនាបថសំបូរព្រៃគុក ព្រៃក្មេង និងកំពង់ព្រះ ដែលមាននៅលើក្បាលជញ្ជាំង លើក្បាច់វិមានអណ្តែត[៥] លើទ្វារបញ្ឆោត និងនៅលើផ្តែរទ្វារក៏មាន (រូបលេខ៣-៤)។

ប្រភេទទី៣៖ ចម្លាក់គូឌុ មានលម្អរូបក្បាលមនុស្សឬទេពនៅខាងក្នុង ដែលយើងឃើញមានឆ្លាក់ច្រើនជាងគេក្នុងសិល្បៈខ្មែរ ទាំងនៅលើឥដ្ឋ និងថ្ម ជាពិសេសរចនាបថសំបូរព្រៃគុក និង

---

[១] Bénisit 1970: 15.

[២] Ghost 1970: 15; Joveau-Dybreull 1914: 60.

[៣] Hardy 1995: 53, 122.

[៤] Stern 1934: 223.

[៥] Chen Chanratana 2006: 91-92.

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

រចនាបថព្រៃក្មេង (រូបលេខ៥-៦)។ ចម្លាក់គូឱប្រភេទទី៣នេះ មានលក្ខណៈពិសេសច្រើនយ៉ាងគួរឱ្យកត់សម្គាល់ តួយ៉ាង គឺរូបភាគច្រើនបែរមុខចំ (រចនាបថសំបូរព្រៃគុក) (រូបលេខ៧) រូបមួយចំនួនបែរមុខចំហៀង (រចនាបថព្រៃក្មេង) (រូបលេខ៨)។ លក្ខណៈពិសេសមួយខ្លាំងនោះគឺ មានរូបខ្លះជាចម្លាក់ជនបរទេស ដូចយើងឃើញនៅចម្លាក់គូឱនៅប្រាសាទក្តារអុកដែលជាសិល្បៈមានឥទ្ធិពលមកពីឥណ្ឌាខាងត្បូងនៅដើមសម័យចលុក្យា ក្នុងតំបន់ដេសង់[៦] (រូបលេខ៩)។

ចម្លាក់គូឱ សិល្បករនិយមប្រើប្រាស់នៅសម័យមុនអង្គរប៉ុណ្ណោះ ប៉ុន្តែចម្លាក់នេះបានវិវឌ្ឍទៅជាផ្នែកមួយនៃកញ្ចាំងក្នុងសិល្បៈខ្មែរសម័យអង្គរ។[៧] ចម្លាក់គូឱ មិនត្រឹមតែដើរតួនាទីជាក្បាច់លម្អរបស់សំណង់សាសនាតែមួយមុខនោះទេ តែជាធាតុផ្សំដ៏សំខាន់ដែលបង្ហាញអំពីការវិវឌ្ឍរបស់សំណង់។[៨]

[៦] Wreyford 2018: 117-141; 333.

[៧] Marchal 1934: 213; 1939: 9.

[៨] Hardy 2007: 63.



រូបលេខ២១៖ ចម្លាក់គូឧលម្អនៅលើក្បាលជញ្ជាំងអមសងខាងក្លោងទ្វារចូលរូងភ្នំដា



រូបលេខ២២៖ ចម្លាក់គូឧលម្អនៅប្រាសាទអាស្រមមហាឥសី ភ្នំដា

អត្ថបទដោយ៖ ម៉ង់ រ៉ាលី



រូបលេខ២៣៖ ចម្លាក់គូឱលម្អនៅទ្វារបញ្ឆោតប្រាសាទជ្រៃ សំបូរព្រៃគុក



រូបលេខ២៤៖ ចម្លាក់គូឱលម្អនៅលើក្បាលជញ្ជាំងប្រាសាទព្រះធាតុក្វាន់ពីរ (រូបថត៖ ញឹម សុជាវិទ្ធ)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ២៥៖ ចម្លាក់គូឌុលម្អនៅលើផ្នែកខាងលើប្រាសាទគុកព្រះធាតុ ភ្នំហាន់ជ័យ

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



*រូបលេខ២៦៖ ចម្លាក់គូឱលម្អនៅលើផ្នែកខាងលើសំណង់គក់គ្រឹះគុកវិហារ N17*



*រូបលេខ២៧៖ ចម្លាក់គូឱរចនាបថសំបូរព្រៃគុកលម្អនៅលើផ្នែកខាងលើសំណង់គក់គ្រឹះគុកវិហារ N17*

*អត្ថបទដោយ៖ ម៉ង់ វ៉ាលី*



រូបលេខ២៨៖ ចម្លាក់គួឱរចនាបថព្រៃក្មេងលម្អនៅលើផ្នែកខាងលើប្រាសាទស្រីគ្រប់លក្ខណ៍



រូបលេខ២៩៖ ចម្លាក់គួឱ “Gāḍha” លម្អដោយរូបជនបរទេសនៅខាងក្នុង នៅប្រាសាទក្ដារអុក S2

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

# ឯកសារយោង

**Bénisti, Mirreille**

1970, *"Rapports entre le premier art Khmer et l'art Indien"* EFEO, Tome I-II, Paris

**Chen Chanratana**

2006, *Etudes des palais volants dans l'art Khmer préangkorien*, Diplôme de Master de recherché Histoire et Archéologie de l'Asie de Sud-est Année, Universite Pariss III-Sorbonne nouvelle UFR orient et Monde Arabe, Paris

**Ghosh, Devaprasad**

1970, *The Chaitya-Window motif,* dan (Banerjea Volumn), Calcutta

**Hardy, Adam**

1995, *Indian temple architecture: Form and transformation,* London

2007*, The temple in southeast asia,* Tome 2, London

**Jouveau-Dybreull, G.**

1914, *Archéologie du Sud de l'Inde*, Tome II, Paris

**Marchal, Henri**

1934, Rapprochements entre l'art khmer et les civilisations polynésiennes et précolombiennes, *Journal de la société des Amémicanistes*, Tome 26, Paris

1939, *La collection Khmère*, EFEO, Hanoi

**Stern, Phillipe**

1934, Évolution du linteau khmer, *revue des Arts Asiatiques*, VIII, Paris